# គ្រូភាសាអង់គ្លេស និងឌីជីថល

**តើអ្នកមានចំណាប់អារម្មណ៍ធ្វើការ ដើម្បីជួយដល់យុវជនដែលបាត់បង់ឱកាស និងក្រុមគ្រួសារពួកគាត់ដែរឬទេ? តើអ្នកចង់ធ្វើការធ្វើការបណ្តុះបណ្តាលដល់កុមារ/យុវវ័យ ឱ្យមានអាជីព និងមុខរបរនៅថ្ងៃអនាគតឬទេ? បើមានចំណាប់អារម្មណ៍ អ្នកអាចមកចូលរួមជាមួយយើងបាន!**

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជាង ១១០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្តល់នូវសេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតវិធីសាស្ត្ររួមមួយចំនួន ដើម្បីគាំទ្រឲ្យកុមារត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ធានាក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញ ឬការងារ ទៅពួកគាត់ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើងបានផ្តល់ការបណ្តុះបណ្តាលជំនាញជាច្រើនដូចជា ចុងភៅ និងសេវាកម្ម សម្អាងកាយ កាត់សក់ ផ្សារដែក អគ្គិសនី។

**តើអ្នកត្រូវធ្វើអ្វី?**

ក្នុងតួនាទីជា **គ្រូភាសាអង់គ្លេស និងឌីជីថល** អ្នកនឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលលើ ជំនាញ និងចំណេះដឹងដែលអាចនឹងឱ្យយុវវ័យ មានអាជីព និងមុខរបរនៅថ្ងៃអនាគត។

**អ្នកនឹងទទួលខុសត្រូវការងារសំខាន់ៗដូចខាងក្រោម៖**

- បង្រៀនជំនាញឌីជីថល និងមូលដ្ឋានភាសាអង់គ្លេសដល់សិស្សថ្នាក់ជំនាញ
- ធានាផ្តល់ការបណ្តុះបណ្តាលស្របតាមកម្មវិធីជំនាញប្រកបដោយគុណភាព
- រៀបចំរបាយការណ៍អភិវឌ្ឍរបស់សិស្សនិងគ្រប់គ្រងឯកសារបណ្តុះបណ្តាល
- សម្របសម្រួលជាមួយអ្នកគ្រប់គ្រងករណីនិងគ្រូជំនាញលើកិច្ចការបង្រៀនរបស់សិស្ស
- ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល និងមូលដ្ឋានភាសាអង់គ្លេសស្របតាមតម្រូវការរបស់ទីផ្សារ
- ធានាសំភារៈបណ្តុះបណ្តាលត្រូវបានថែរក្សាយ៉ាងល្អនិងបច្ចុប្បន្នភាពទាន់ទីផ្សារ
- គ្រប់គ្រងថ្នាក់បង្រៀនឌីជីថល អនាម័យ ស្តុកសំភារៈបង្រៀននិងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- រៀបចំបោះ ពុម្ពលិខិតបញ្ជាក់ការសិក្សា និងវិញ្ញាបនបត្រសម្រាប់សិស្សជំនាញ
- រៀបចំរបាយការណ៍បណ្តុះបណ្តាល និងឯកសារហិរញ្ញវត្ថុ

**យើងត្រូវការអ្នកដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- អ្នកមានបរិញ្ញាបត្រភាសាអង់គ្លេស ឬកុំព្យូទ័រ
- បទពិសោធន៍ពាក់ព័ន្ធនឹងការបង្រៀនយ៉ាងតិច ០១ឆ្នាំ
- អ្នកចូលចិត្តធ្វើការងារជាមួយកុមារ/យុវវ័យ
- អ្នកមានមានជំនាញក្នុងការទំនាក់ទំនង អាចធ្វើការងារជាក្រុម មានភាពអត់ធ្មត់ ចេះបត់បែន

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្ត

សំឡាញ់ អាស័យដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ។ **សូមបញ្ជាក់ពីតួនាទីដែលអ្នកចង់ដាក់ពាក្យ និងប្រាក់បៀវត្សរ៍ពឹងទុក។**
ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។ បេក្ខជនទាំងអស់នឹងត្រូវឆែកប្រវត្តិរូប ដើម្បីអនុលោមតាមគោលការណ៍ កិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(PSEA)។

ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី**១១ ខែមេសា ឆ្នាំ២០២៤**។